ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៣៣១

ចុះថ្ងៃទី ២៩_០៦_២០០៩

សាលដីកា

លេខ : ៤០ "ខ"

ចុះថ្ងៃទី ២១_០៤_២០១០

ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២១-០៤-២០១០ ដោយមានសមាសភាពដូចខាងក្រោម:

ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted]

ក្រឡាបញ្ជី

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៣៣១ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ ៤៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិគាស់ក្រឡ ឃុំគាស់ក្រឡ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ទីលំនៅ[redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ[redacted] (ស) ម្តាយឈ្មោះ[redacted] ប្រពន្ធឈ្មោះ ឈើយ [redacted] មានកូន ៩នាក់ ទោសពីមុនគ្មាន។

ត្រូវជាប់ចោទពីបទ: បរិយាកេរ្តិ៍ និងជេរប្រមាថ ប្រព្រឹត្តនៅភូមិកន្ទួត ឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី ២២ ខែសីហា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]រើន ភេទស្រី អាយុ ៣៩ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិកន្ទួត ឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កើត ហៅ ហាក់ ភេទប្រុស អាយុ ៤៦ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិកន្ទួត ឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៤ ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០០៩ របស់ឈ្មោះ[redacted] ចាន់ ជាជនជាប់ចោទ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១០ "ឆ" ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទី ១ នៃសេចក្តីសម្រេច។



Scanned with CamScanner

ដំណើររឿងមានដូចតទៅ:

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២២-២៣ ខែសីហា ឆ្នាំ២០០៧ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំរើន និង ឈ្មោះ [redacted] កើត ថា ឈ្មោះ [redacted] ចាន់ នេះ បានមូលបង្កាច់ និងបង្ខូចកិត្តិយសដល់រូបខ្លួនទាំងពីរថា បានរួមរក្សត្តនៅលើ ថ្នល់ភូមិកន្ទួត ឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១០ "ឆ" ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ដែលបានសម្រេចសេចក្តីដូចខាងក្រោម:

១- ផ្តន្ទាទោសឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ ៤៧ឆ្នាំ ពិន័យជាប្រាក់ចូលថវិការដ្ឋចំនួន ១លានរៀល និងបង្គាប់ឱ្យឈ្មោះនេះសងសំណងថ្លៃជម្ងឺចិត្តចំនួន ១លាន ៥សែនរៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំរើន និង ១លាន ៥សែនរៀល ទៀត ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កើត ហៅ ហាក់ ការសុំលើសពីនេះបដិសេធចោល ពីបទ បរិហាកេរ្តិ៍ ប្រព្រឹត្តនៅភូមិកន្ទួត ឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី ២២ ខែសីហា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវបណ្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៤ ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ចាន់ ជាជនជាប់ចោទ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១០ "ឆ" ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទី ១ នៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ចាន់ បានឆ្លើយនៅសាលាដំបូងខេត្តបាត់ដំបង។

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កើត បានឆ្លើយនៅសាលាដំបូងខេត្តបាត់ដំបង។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំរើន ឆ្លើយថា: ជនជាប់ចោទឈ្មោះ [redacted] ចាន់ ពិតជាបានបរិហាកេរ្តិ៍ខ្លួនមែន។ សំណូមពរ សុំតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង។

សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

មហាអយ្យការសាលាឧទ្ធរណ៍សូមសន្និដ្ឋានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០ "ឆ" ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កើត



Scanned with CamScanner

- ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ច័រើន
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់ ។

<u>សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា៖</u>

១- បណ្តឹងឧទ្ធរណ៍លេខ ៣៤ ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០០៩ របស់ឈ្មោះ[redacted] ចាន់ ជាជនជាប់ចោទ ធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។

២- ជនជាប់ចោទថា ខ្លួនគ្រាន់តែបាននិយាយតាមពាក្យឈ្មោះ[redacted]តង់ ជាប្រពន្ធរបស់ឈ្មោះ [redacted] គ្នាជាមួយប្តីអញប៉ុណ្ណោះ មិនបាននិយាយអ្វីផ្សេងទៀតទេ ។

៣- តាមចម្លើយឈ្មោះ[redacted] ច័រើន និងឈ្មោះ [redacted] កើត ហៅ [redacted] ជាដើមបណ្តឹងថា ជនជាប់ចោទពិតជាបាននិយាយបរិហាកេរ្តិ៍ខ្លួនទាំងពីរនាក់ថា បានរួមរ័ក្សនឹងគ្នាលើថ្នល់ប្រាកដមែន ។

៤- មានពិរុទ្ធលើជនជាប់ចោទ ពីបទ បរិហាកេរ្តិ៍ ប្រព្រឹត្តនៅភូមិកន្ទួត ឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង កាលពីថ្ងៃទី ២២ ខែសីហា ឆ្នាំ២០០៧ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមច្បាប់ស្តីពីវិសោធនកម្មមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៥- សាលក្រមព្រហ្មទណ្ឌលេខ ១០ "អ" ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៤ ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted]ចាន់ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០ "អ" ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ចែងបង្គាប់ចំពោះមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងអាជ្ញាធរគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណុមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា: [redacted] [redacted] | ហត្ថលេខា [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី30 ខែ12 ឆ្នាំ២០១០
ក្រឡាបញ្ជី



Scanned with CamScanner